# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*លាតត្រដាងការសម្លាប់នឹងនាំឲ្យបាត់បង់ជីវិត។*

*រក្សាការសម្លាត់នឹងទទួលបានជ័យជំនះ ៨០%។*

*សាក្សី* ***សាឡុត បាន***

## I. និជ្ជនាពន្ធនៅ

នៅសប្តាហ៍នេះ គឺដល់វេនរបស់ក្រុមមេធាវីការពារក្តីក្នុងការសួរដេញដោលសាក្សី **សាឡុត បាន** ដែលត្រូវជាក្មួយប្រុសរបស់ **ប៉ុល ពត** ។ សាក្សី គឺជាអគ្គលេខាធិការនៃក្រសួងការបរទេសនៅក្នុងរបបកម្ពុជាប្រជាធិបេតយ្យ។ ទន្ទឹមនឹងភាពរហ័សរហួនក្នុងការឆ្លើយសំណួរ សាក្សី **សាឡុត បាន** នៅតែរក្សាជំហរថា **ប៉ុល ពត** គឺជា “ម្ជុលមួយក្នុងសមុទ្រ” ដែលមានន័យថា **ប៉ុល ពត** មិនបានធ្វើការសម្រេចចិត្តតែម្នាក់ឯងនោះទេ។ សាក្សី **សាឡុត បាន** ក៏បានពន្យល់អធិប្បាយពីទស្សនៈស្តីពី “ប្រជាធិបតេយ្យប្រមូលផ្តុំ” ហើយបានផ្តល់ការរៀបរាប់លម្អិតអំពីបក្សកុម្មុយនីស្តឥណ្ឌូចិន និង “អង្គការ”។ សាក្សីបានផ្តល់ព័ត៌មានស្តីពីតួនាទីរបស់មន្ត្រីខ្មែរក្រហមជាន់ខ្ពស់ពីររូប គឺ **ឈឹម សំអោក** ហៅ “សមមិត្ត **ប៉ង់**” និង **ជាម**[1] ដែលគេស្គាល់ត្រឹមថាជាអ្នកធ្វើការនៅក្រសួងការបរទេស។

បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សាដេញដោលសាក្សី **សាឡុត បាន** សាក្សីមួយរូបទៀតដែលជាអតីតអង្គរក្ស **កុយ ធួន**[2] (សាក្សី **ពាន ឃាន**) ត្រូវបានកោះហៅមកផ្តល់ចម្លើយផងដែរ នាសប្តាហ៍នេះ។ តំណាងសហព្រះរាជអាជ្ញា ដែលមានលោក **ថារីក អាប់ឌុលឡាក់** និងលោក **វាំងសង់ វ៉ាយដ៍ ដេស្នាឯល** បានសួរដេញដោលសាក្សី ១-អំពីរចនាសម្ព័ន្ធរដ្ឋបាល ២-ទំនាក់ទំនងនៅក្នុងកងសន្តិសុខរបស់គាត់ និង ៣-តួនាទី

របស់ជនជាប់ចោទទាំងបីរូប។ សាក្សី **ពាន ឃាន** ជាសមាជិកមួយរូបនៃជនជាតិដើមភាគតិច “ខ្មែត” គាត់បានពិពណ៌នាអំពីបទពិសោធន៍របស់ខ្លួន ក្នុងនាមជាអង្គរក្ស ជានិរសារ និងជាអ្នកដឹកជញ្ជូនបន្លែបង្កានៅរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សីក៏បានរ៉ាយរ៉ាប់នូវតួនាទី និងមុខងាររបស់មន្ទីរ ក-១ និងមន្ទីរ ក-៣។ ក្នុងនាមជាជំនិតនៃរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃរបបខ្មែរក្រហម **កុយ ធួន** ហៅ “**ធុច**” និងកម្មាភិបាលជាន់ខ្ពស់ **ប៉ង់** ធ្វើឲ្យសាក្សីរូបនេះអាចផ្តល់ការបំភ្លឺមួយចំនួន ស្តីពីរចនាសម្ព័ន្ធនាពេលនោះ។

ដោយបញ្ហាសុខភាពរបស់សាក្សីពុំអំណោយផល អង្គជំនុំជម្រះបានបង្ខំចិត្តប្រកាសបញ្ចប់នីតិវិធីមុនពេលកំណត់ គឺនៅត្រឹមកិច្ចពិភាក្សាវគ្គទី២នៃថ្ងៃព្រហស្បតិ៍។ សាក្សីត្រូវបានតម្រូវឲ្យត្រឡប់មកផ្តល់សក្ខីកម្មជាបន្តនៅថ្ងៃទី១៧ ឧសភា ២០១២។

## II. សេចក្តីសង្ខេបអំពីសក្ខីកម្មរបស់សាក្សី

សាក្សី **សាឡុត បាន** បានបន្តសក្ខីកម្មក្រោមការឆ្លើយតបនឹងសំណួរ របស់មេធាវីការពារក្តីទាំងបីក្រុម កាលពីថ្ងៃច័ន្ទ ទី៣០ មេសា ២០១២ និងអំឡុងពេលកិច្ចពិភាក្សាដេញដោលវគ្គទី១ នាថ្ងៃពុធ ទី២ ឧសភា ២០១២។ មេធាវីការពារក្តី បានផ្តោតសំខាន់ទៅលើសក្ខីកម្មរបស់សាក្សី ដែលបានផ្តល់កាលពីសប្តាហ៍មុន ថាតើសក្ខីកម្មនោះមានភាពប្រាកដប្រជាបានត្រឹមកម្រិតណា។

អង្គជនុំជម្រះក៏បានកោះហៅសាក្សីម្នាក់ទៀតចូលមកផ្តល់សក្ខីកម្ម ក្រោយការបញ្ចប់កិច្ចពិភាក្សាជាអសាធារណៈ ស្តីពីបញ្ហាប្រឈមចំពោះការមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ សាក្សី **ពាន ឃាន** បានផ្តល់សក្ខីកម្ម នៅថ្ងៃទី២ ឧសភា ២០១២ ផ្តោតសំខាន់ អំពីការចូលរួមបដិវត្តន៍ តួនាទីដំបូងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ការបម្រើការក្រោមបញ្ជា **កុយ ធួន** និងប្រពន្ធរបស់ **កុយ ធួន** ។ សាក្សីបានបរិយាយឲ្យដឹងថា គាត់បានមកដល់ទីក្រុងភ្នំពេញនៅពីថ្ងៃទី១៧ មេសា ១៩៧៥ គឺនៅចំថ្ងៃជម្លៀសប្រជាជន។ ចំណែកឯនៅថ្ងៃសវនាការបន្ទាប់ នៅក្នុងកិច្ចពិភាក្សាវគ្គទី១ សាក្សី **ពាន ឃាន** បានឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធនឹងតួនាទីរបស់ខ្លួន ក្រោយថ្ងៃកាន់កាប់ទីក្រុងភ្នំពេញ និងការចាប់ខ្លួន **កុយ ធួន**។

### ក. សក្ខីកម្មបន្តរបស់សាក្សី សាឡុត បាន

តាមរយៈសក្ខីកម្មរបស់សាក្សីកាលពីសប្តាហ៍មុន ក្រុមមេធាវីការពារក្តីបានចម្រាញ់នូវសំណួរមួយចំនួន ដើម្បីសួរបំភ្លឺឲ្យច្បាស់ពីសេចក្តីថ្លែងទាំងនោះ ដោយជ្រើសរើសតែចំណុចទាំងឡាយណា ដែលគាំទ្រដល់គោលជំហររបស់ខ្លួន និងបន្ទាបតម្លៃព័ត៌មានដែលធ្វើឲ្យខូចដល់ប្រយោជន៍ដល់កូនក្តី ។

មេធាវីការពារក្តីលោក **អៀង សារី** បានព្យាយាមពន្លៀតនូវមន្ទិលសង្ស័យចំពោះសក្ខីកម្មរបស់សាក្សី **សាឡុត បាន** ដែលថា **ប៉ុល ពត** “គឺជាម្ជុលមួយនៅក្នុងសមុទ្រ” ដោយសំអាងថា លោក **អៀង សារី** ក៏មានការភ័យខ្លាចដែរ នៅកំឡុងពេលដែលគាត់កាន់តំណែង។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីលោក **នួន ជា** បានចោទសួរសាក្សីថា តើបានដឹងអំពីអត្តចរិតរបស់លោក **នួន ជា**? អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា? និងអំពីការជ្រៀតជ្រែកចូលផ្នែកនយោបាយនៅក្នុងសំណុំរឿង ០០២។ រីឯមេធាវី **គង់ សំអុន** ដែលជាមេធាវីជាតិការពារក្តីលោក **ខៀវ សំផន** បានផ្តោតសំណួររបស់គាត់ទៅលើការបង្កើតទីបញ្ជាការបក្សកុម្មុយនីស្តកម្ពុជា (ដែលមានទីតាំងនៅក្នុងព្រៃ) និងគោលការណ៍រក្សាការសម្ងាត់ ដែលបានអនុវត្តនៅក្នុងគណបក្សកុម្មុយនីស្តកម្ពុជា។ តាមរយៈសក្ខីកម្មរបស់សាក្សី **សាឡុត បាន** បានឲ្យដឹងថា លោក **ខៀវ សំផន** ហាក់ដូចជាពុំមានអំណាចទេនៅក្នុងសម័យនោះ។

### ១. “អង្គការ” និង សេចក្តីសម្រេចក្នុងបក្សកុម្មុយនីស្តកម្ពុជា

តាមរយៈសាក្សី **សាឡុត បាន** “អង្គការ” គឺជាបណ្តុំនៃការចូលរួមពីសំណាក់មហាជនគ្រប់ស្រទាប់វណ្ណៈ។ ផ្ទុយទៅវិញ ទោះបីជាមេធាវី **កាណារាស** បានដាក់ការទទួលខុសត្រូវទាំងស្រុងលើ **ប៉ុល ពត** ក៏ចម្លើយសាក្សី **សាឡុត បាន** បានឲ្យដឹងថា “អង្គការមិនមែនសំដៅតែទៅលើឪពុកមារខ្លួនតែម្នាក់ទេ។ សាក្សីបានលើកឡើងថា **ប៉ុល ពត** មិនបានធ្វើសេចក្តីសម្រេច ដោយឯកឯងក្នុងមុខការបក្សកុម្មុយនីស្តកម្ពុជា រាល់ការសម្រេចចិត្ត គឺអនុលោមតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ដែលមតិភាគតិចគោរពតាមមតិភាគច្រើន។ សាក្សីបានអធិប្បាយថា គាត់បានដឹងពីគោលការណ៍ និងពាក្យ “អង្គការ” តាមរយៈវគ្គសិក្សារៀនសូត្រ ប៉ុន្តែគាត់មិនធ្លាប់បានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នោះទេ។ ទោះជាយ៉ាងណាសាក្សីបានឲ្យដឹងថា រាល់ការសម្រេចចិត្ត គឺធ្វើឡើងជារួម (ជាសមូហភាព) និងប្រដូចថា “**ប៉ុល ពត** គឺជាម្ជុលមួយនៅក្នុងសមុទ្រ ចំណែកឯរូបគាត់ គឺជាដំណក់ទឹកមួយនៅក្នុងសមុទ្រ”។

### ២. ក្រសួងការបរទេស

សាក្សី **សាឡុត បាន** ធ្លាប់ជាអគ្គលេខាធិការនៃក្រសួងការបរទេសនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ សាក្សីបានអះអាងថា ទោះបីជាឋានៈនេះមានត្រឹមតែឈ្មោះក៏ដោយ ក៏គាត់មានការប្រាស្រ័យទាក់ទងជាមួយចៅហ្វាយនាយខ្លួនជាញឹកញាប់ គឺ **ប៉ង់** និងលោក **អៀង សារី**។ ចំណែកឯ **ជាម** ដែលប្រហែលជាបុគ្គលធ្វើការក្រោមបង្គាប់គាត់នៅក្រសួងការបរទេស សាក្សីបានប្រាប់ថា ពាក់ព័ន្ធបញ្ហាសន្តិសុខ **ជាម** ស្ថិតក្រោមបញ្ជាផ្ទាល់របស់ **ប៉ង់** ។ **ជាម** ជាអ្នកដឹកជញ្ជូនមនុស្សដែល **ប៉ង់** កំណត់យកចេញពីក្រសួងការ

បរទេស។ សាក្សី **សាឡុត បាន** បានអះអាងថា គាត់មិនបានដឹងពីការចាប់ខ្លួនមនុស្សនៅក្រសួងការបរទេស ហើយគាត់មានការភ័យខ្លាច ចំពោះសុវត្ថិភាពរបស់ខ្លួន និងក្រុមគ្រួសារជាខ្លាំង។ សាក្សីរៀបរាប់ថា ៖

> *អារម្មណ៍នៅពេលនោះ គឺខ្ញុំគិតពីគ្រួសារ រួមទាំងឪពុកម្ដាយ ដែលកំពុងស្ថិតក្នុងស្ថានការណ៍គ្រោះថ្នាក់ដូចអ្នកដទៃទៀត។ វាជាអារម្មណ៍ពិតរបស់ខ្ញុំ! ហើយខ្ញុំក៏មានការព្រួយបារម្ភចំពោះខ្លួនឯងដែរ ប្រសិនបើខ្ញុំត្រូវបានគេរកឃើញថា ខ្ញុំបាននិយាយ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយ* ***ជាម*** *នៅពេលដែល* ***ជាម*** *បានកំពុងអនុវត្តបញ្ជារបស់* ***ប៉ង់*** *ខ្ញុំអាចមានគ្រោះថ្នាក់ ព្រោះថាអ្នកផ្សេងអាចភ័ន្តច្រលំថា ខ្ញុំមានទំនាក់ទំនងជាមួយ* ***ប៉ង់*** *និងគិតថា ខ្ញុំជាប់ពាក់ព័ន្ធជាមួយមនុស្សដែល* ***ជាម*** *ចាប់យកចេញទៅ។ នៅពេលគិតពីរឿងទាំងនេះ ខ្ញុំមានការព្រួយបារម្ភណាស់។*

ទំនាក់ទំនងជាប់សាច់ញាតិជាមួយ **ប៉ុល ពត** មិនបានបញ្ឈប់ភាពភ័យខ្លាចនោះទេ ដោយសារសាក្សីដឹងច្បាស់ថា “**ប៉ុល ពត** គ្មានមនោសញ្ចេតនាសាច់ញាតិ និងគ្មានគ្រួសារនិយម” ក្នុងនាមជាក្មួយបង្កើតក៏អាចត្រូវចាប់ខ្លួនដែរ។

មេធាវីការពារក្ដីលោក **អៀង សារី** បានបូកសរុបសក្ខីកម្មនេះថា លោក **អៀង សារី** ក៏មានការភ័យខ្លាចដែរ។ មេធាវីបានដកស្រង់ចំណុចដែលសាក្សី **សាឡុត បាន** ថ្លែងថា លោក **អៀង សារី** “ខ្លួនគាត់ផ្ទាល់ក៏មានការភ័យខ្លាច” ព្រមទាំងលើកឡើងពីការស្លាប់របស់ **ខៀវ ធីរ៉ាត់** ដែលជាប្អូនស្រីរបស់លោកស្រី **អៀង ធីរិទ្ធ** គឺបង្ហាញថា គ្មាននរណាម្នាក់មានសុវត្ថិភាពទេក្នុងរបបនោះ។ សាក្សី **សាឡុត បាន** បានឲ្យដឹងថា តាមរយៈទឹកមុខរបស់លោក **អៀង សារី** នាពេលនោះ គឺអាចបញ្ជាក់ថា ចៅហ្វាយខ្លួនមានភាពក្រៀមក្រំដោយសារហេតុការណ៍កើតឡើងនៅក្នុងក្រសួងការបរទេស។

សាក្សីបានបំភ្លឺដដែលថា នៅពេល **អៀង សារី** អានចម្លើយសារភាពរបស់ **កុយ ធួន** ប្រាប់ដល់បុគ្គលិកក្រសួងការបរទេស “អ្នកគ្រប់គ្នាមិនថាតែលោក **អៀង សារី** និងរូបខ្ញុំ ព្រមទាំងអ្នកផ្សេងទៀត មានការភិតភ័យយ៉ាងខ្លាំង”។ ទោះជាយ៉ាងណាសាក្សី **សាឡុត បាន** បានបញ្ជាក់ថា គាត់ហាក់មានភាពមន្ទិលសង្ស័យទៅលើចម្លើយសារភាពនោះ ព្រោះរាល់ការសារភាពពុំបានឆ្លុះបញ្ចាំងពីជីវភាពរបស់ **កុយ ធួន** នោះទេ ហាក់ដូចជាចម្លើយសារភាពរបស់បុគ្គលម្នាក់ទៀត។

***លោក គាត ឈន់ និងលោក ហោ ណាំហុង*** ៖ ស្ទើរតែគ្រប់ពេល មេធាវី **មីឃៀល ផេស្កមេន** ដែលជាមេធាវីការពារក្តីលោក **នួន ជា** បានសួរដេញដោលសាក្សី **សាឡុត បាន** ពីអតីតមន្ត្រីក្រសួងការបរទេសក្នុងរបបនោះ ពីររូប ដែលបច្ចុប្បន្ន ពួកគាត់ជាមន្ត្រីជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាល គឺ ឯកឧត្តម **គាត ឈន់** និងឯកឧត្តម **ហោ ណាំហុង**។ មេធាវី **ផេស្កមេន** បានសាកសួរអំពីតួនាទី និងឋានៈរបស់អ្នកទាំងពីរនាពេលនោះ។ បន្តបន្ទាប់ទៀត ថាតើសាក្សីបានដឹងថា លោក **គាត ឈន់** បានអមដំណើរសម្តេចព្រះបាទសីហនុទៅទីក្រុងញូយ៉ក នៅឆ្នាំ១៩៧៥។ អង្គជំនុំជម្រះយល់ឃើញថា សំណួរទាំងនោះពុំមានភាពពាក់ព័ន្ធ និងបានណែនាំសាក្សីមិនឲ្យឆ្លើយតបនឹងសំណួរ។ ទោះបីជាយ៉ាងណា មេធាវីបានបន្តលើកបង្ហាញតារាងមួយ ដែលរៀបចំដោយការិយាល័យព្រះរាជអជ្ញា បង្ហាញថា លោក **ហោ ណាំហុង** មានតួនាទីពីរយ៉ាងសំខាន់នៅក្នុងរបបខ្មែរក្រហម គឺជាឯកអគ្គរាជទូតប្រចាំប្រទេសគុយបា និងប្រធានមន្ទីរបឹងត្របែក ឆ្លើយតបទៅនឹងសំណួរនេះ សាក្សីបានបដិសេធថា ខ្លួនមិនដែលបានឃើញតារាងនេះពីមុនទេ។ ចំពោះសំណួរដែលថា ហេតុអ្វីបានជាលោក **ហោ ណាំហុង** ត្រូវបានផ្តល់ផ្ទះមួយកន្លែងនៅក្បែរវិមានឯករាជ្យ សាក្សី **សាឡុត បាន** បានរៀបរាប់ទាំងមិនច្បាស់ថា នៅពេលនោះកងទ័ពវៀតណាមបានចូលមកកៀកហើយ ហើយគាត់ពុំបានដឹងថា តើ **ប៉ង់** នៅទីណានោះទេ ដូច្នេះ ក្រសួងការបរទេស បានស្នើសុំឲ្យលោក **ហោ ណាំហុង** ទៅរស់នៅវីឡានោះជំនួស។ មេធាវី **ផេស្កមេន** បានបន្តសួរសាក្សីថា តើគាត់ធ្លាប់មានទំនាក់ទំនងជាមួយលោក **គាត ឈន់** និងលោក **ហោ ណាំហុង** និងតើសាក្សីបានដឹងថា អ្នកទាំងពីរត្រូវបានកោះហៅមកផ្តល់សក្ខីកម្មដែរឬទេ។ លោកមេធាវីក៏បន្តសួរថា តើសាក្សីបានដឹងពីមូលហេតុដែលនាំឲ្យអ្នកទាំងពីរបដិសេធមិនព្រមមកផ្តល់សក្ខីកម្ម នៅការិយាល័យសហចៅក្រមស៊ើបអង្កេត (ដោយសារតែភាពភ័យខ្លាច ឬ ដោយសារតែមានការបញ្ជាពីគណបក្សប្រជាជន ឬសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន**)។ អង្គជំនុំជម្រះបានធ្វើអន្តរាគមន៍ម្តងទៀត និងណែនាំសាក្សីមិនឲ្យឆ្លើយតបនឹងសំណួរទាំងនោះ ដោយសម្រេចថា សំណួរទាំងនេះមិនមានភាពពាក់ព័ន្ធនឹងដំណើរការនីតិវិធី។

### ៣. ទីបញ្ជាការរបស់បក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥

មេធាវី **គង់ សំអុន** ដែលជាមេធាវីការពារក្តីលោក **ខៀវ សំផន** បានដេញដោលសួរសាក្សី អំពីទីបញ្ជាការរបស់បក្សកុម្មុយនីស្តកម្ពុជាមុនចូលកាន់កាប់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥។ សាក្សី **សាឡុត បាន** បានអះអាងថា ទីបញ្ជាការរបស់បក្សកុម្មុយនីស្ត បានត្រូវផ្លាស់ប្តូរជាច្រើនដងនៅមុនឆ្នាំ១៩៧៥ ដែលការផ្លាស់ប្តូរចុងក្រោយ ប្រហែលជានៅ ឆ្នាំ១៩៧៣ ឬ ១៩៧៤។ ទីបញ្ជាការត្រូវបានសាងសង់ឡើងនៅក្នុងព្រៃជ្រៅ គឺដើម្បីរក្សាពីភាពសម្ងាត់។ បន្ថែមលើនោះ សាក្សីបានពិពណ៌នាយ៉ាងលម្អិត អំពីរចនាសម្ព័ន្ធ និង

ទីតាំងនៃទីបញ្ជាការថា ជាកូនខ្ទមតូចៗ ដែលមានអ្នកយាមនៅជុំវិញ និងល្បាតនៅក្បែរនោះ។ រីឯកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំពុំមានការចូលរួមស្តាប់ពីអ្នកយាម ឬអ្នកផ្សេងឡើយ ។

## ៤. គោលនយោបាយ និងការអនុវត្តន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

មេធាវី **សុន អារុណ** ដែលជាមេធាវីការពារក្តីលោក **នួន ជា** បានផ្តោតសំណួររបស់ខ្លួនសំខាន់ទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងបទពិសោធន៍របស់សាក្សីក្នុងការអនុវត្តន៍គោលនយោបាយទាំងនោះ ខណៈដែលមេធាវី **គង់ សំអុន** បានសួរដេញដោលសាក្សី អំពីការអនុវត្តន៍គោលការណ៍សម្ងាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

### ៤.១. សហករណ៍

នៅពេលដេញដោលពីបញ្ហាកង្វះខាតស្បៀងអាហារនៅក្នុងសហករណ៍ សាក្សីបានឲ្យដឹងថា បញ្ហាលំបាករបស់ប្រជាពលរដ្ឋ គឺដោយសារមនុស្សអាក្រក់មួយចំនួន ពុំបានអនុវត្តទៅតាមបញ្ជារបស់ថ្នាក់លើ ដែលបានបំផ្លាញចេតនាល្អរបស់អង្គការ គឺថា “ថ្នាក់លើបានណែនាំឲ្យផ្តល់របបបង្អែមមួយដងក្នុងមួយអាទិត្យ” ប៉ុន្តែ គោលការណ៍នេះពុំត្រូវបានអនុវត្តទេ។ ផ្ទុយទៅវិញ ស្រូវអង្ករត្រូវបានដឹកជញ្ជូនទៅកន្លែងផ្សេងៗ ឬត្រូវដុតបំផ្លាញចោល។ សាក្សីបានឲ្យដឹងថា ជាពិសេសថ្នាក់លើរបស់គាត់បានបញ្ជាឲ្យផ្តល់សំលៀកបំពាក់ដល់ប្រជាជនប្រើប្រាស់ ប៉ុន្តែក៏ត្រូវដុតបំផ្លាញដែរ។ គាត់បានដឹងពីរឿងរ៉ាវទាំងនេះ គឺយឺតពេលទៅហើយ។ សាក្សីបាននិយាយថា មនុស្សមិនល្អទាំងនោះ “បានបំផ្លាញកេរ្តិ៍ឈ្មោះអង្គការ” ព្រោះពួកគេស្អប់ និងចង់បំផ្លាញអង្គការទាំងមូល។ ទោះជាយ៉ាងណា សាក្សីបានបដិសេធមិនធ្វើការបរិយាយលម្អិតថាតើនរណាជាមនុស្សអាក្រក់នោះទេ។

### ៤.២. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

យោងតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីបានរៀបរាប់ថា តាមពិតគាត់បានដឹងព័ត៌នេះតាមរយៈទាហាន ដែលថា មូលហេតុនៅក្រោយការជម្លៀសប្រជាជន គឺដោយសារតែភ្នាក់ងារស៊ើបការរបស់ចក្រពត្តិអាមេរិកនៅទីក្រុង។ សាក្សីក៏បន្តថា ទីក្រុងត្រូវបានជម្លៀស ក៏ព្រោះអាមេរិកមានបំណងចង់ទម្លាក់គ្រាប់បែក និងធ្វើការវាយប្រហារទីក្រុងភ្នំពេញ។ សាក្សី **សាឡុត បាន** នៅតែបញ្ជាក់ថា គាត់ពុំបានដឹងពីគម្រោងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បើទោះជា គាត់ដឹងថា មានការប្រជុំពីថ្នាក់ដឹកនាំនៅឯទីបញ្ជាការអំពីផែនការទាំងនេះ។

### ៤.៣. គោលនយោបាយលើជនជាតិភាគតិច

សាក្សីនៅតែរក្សាសក្ខីកម្មរបស់ខ្លួនថា បុគ្គលគ្រប់រូបត្រូវតែរួបរួមគ្នា ដើម្បីវាយប្រឆាំងនឹងចក្រពត្តិអាមេរិក មិនថាពួកគេជាសមាជិកជនជាតិភាគតិចណាមួយនោះទេ។ សាក្សីបញ្ជាក់ថា នៅពេលនោះ ជនជាតិចាមពុំត្រូវបានធ្វើទុក្ខទោសនោះឡើយ។

### ៤.៤. គោលការណ៍រក្សាការសម្ងាត់

ឆ្លើយតបសំណួរពាក់ព័ន្ធនឹងគោលការណ៍រក្សាការសម្ងាត់ ដែលបានអនុវត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងក្នុងរបបកម្ពុជាប្រជាធិតេយ្យ សាក្សី **សាឡុត បាន** បានបង្ហាញថា សមាជិកម្នាក់ៗដឹងត្រឹមតែការងាររបស់ខ្លួនប៉ុណ្ណោះ និងពុំបានដឹងពីការងាររបស់ថ្នាក់លើឡើយ។ សាក្សីបានលើកឡើងនូវពាក្យស្លោករបស់បក្សកុម្មុយនីស្តមួយថា *"លាតត្រដាងការសម្ងាត់នឹងនាំឱ្យបាត់បង់ជីវិត។ រក្សាការសម្ងាត់នឹងទទួលបានជ័យជំនះ ៨០%"*។

### ៤.៥. ទំនាក់ទំនងជាមួយលោក នួន ជា និងលោក ខៀវ សំផន

ទោះបីសាក្សី **សាឡុត បាន** បានធ្វើការជាប់រហូតជាមួយលោក **អៀង សារី** នៅក្នុងរបបនោះ ក៏នៅពេលខ្លះគាត់មានឱកាសជួបលោក **នួន ជា** ដែរ គឺនៅឯខេត្តរតនៈគីរី។ សាក្សីបានឲ្យដឹងថា គាត់មិនធ្លាប់ធ្វើការជាមួយលោក **នួន ជា** ទេ ប៉ុន្តែលោក **នួន ជា** ល្អជាមួយគាត់ណាស់។ លោក **នួន ជា** បានផ្តល់ដំបូន្មានណែនាំដល់សមាជិកឲ្យចេះស្រឡាញ់គ្នាទៅវិញទៅមក និងបានអប់រំពួកគេដើម្បីបន្តការស្នេហាបដិវត្តន៍។ ចំណែកឯទំនាក់ទំនងជាមួយលោក **ខៀវ សំផន** វិញ គឺហាក់ដូចជាពុំមានទាល់តែសោះ ប៉ុន្តែសាក្សីបានធ្វើការអះអាងថា អតីតប្រមុខរដ្ឋ "ពុំមានសិទ្ធិអំណាចទេ"។

### ៤.៦. ទំនាក់ទំនងជាមួយ ប៉ុល ពត ក្រោយខែមករា ១៩៧៩

សាក្សី **សាឡុត បាន** បានផ្តល់សក្ខីកម្មថា នៅពេលកងទ័ពវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ គាត់ត្រូវបានតម្រូវឲ្យរក្សាមនុស្សជាង ១០០០នាក់ នៅក្រសួងការបរទេស ដោយមិនឲ្យមានគ្រោះថ្នាក់អ្វីឡើយ និងបានគេចខ្លួនទៅភាគបស្ចិមឆ្ពោះទៅកាន់ព្រំដែនថៃ។ សាក្សីបានឲ្យដឹងថា គាត់បានជួប **ប៉ុល ពត** មួយឆ្នាំក្រោយមក ប៉ុន្តែពួកគេមិនស្នាក់នៅជាមួយគ្នាទេ។ នៅពេល **ប៉ុល ពត** ធ្លាក់ខ្លួនឈឺ គាត់បានកោះហៅសមាជិកទាំងអស់ និងប្រាប់ពួកគេថា ស្ថានការណ៍មិនល្អទេ ព្រមទាំងឲ្យខ្លួនដែលជាក្មួយបង្កើតទៅលាក់ខ្លួន និងបង្ហាញមុខ នៅពេលគាត់ហៅប៉ុណ្ណោះ។ ចាប់ពីពេលនោះមក គាត់ពុំបានឃើញពូរបស់គាត់ទៀតទេ ប៉ុន្តែគាត់បានទៅគោរពបូជានៅឯផ្នូររបស់គាត់ ។

### ៤.៧. ភាពមន្ទិលសង្ស័យ និង ភាពជឿជាក់បាននៃសក្ខីកម្ម

សក្ខីកម្មរបស់សាក្សីធ្វើឡើងដោយស្មោះត្រង់ បើទោះជានៅពេលខ្លះសាក្សីបានសម្តែងនូវការបិទភ្នែក ដើម្បីជញ្ជឹងគិត ឬព្យាយាមរកនឹកនូវព្រឹត្តិការណ៍ឡើងវិញ។ ចម្លើយមួយចំនួនរបស់សាក្សីហាក់មានលក្ខណៈទស្សនៈនិយម ឬមានជំនឿជ្រុលហួសហេតុ។ ចំណុចដែលគួរយកចិត្តទុកដាក់នោះ គឺថា ភាពមិនស៊ីសង្វាក់រវាងសក្ខីកម្ម និងភស្តុតាងមួយចំនួន បានបង្កឲ្យមានមន្ទិលសង្ស័យលើភាពជឿជាក់នៃសក្ខីកម្មរបស់សាក្សីរូបនេះ។

ជាឧទាហរណ៍ ៖ សាក្សីនៅតែបន្តលើកឡើងម្តងហើយម្តងទៀតថា **ប៉ង់** ធ្វើការនៅក្រសួងការបរទេសរហូតកងទ័ពវៀតណាមចូលមកដល់ នៅខែមករា ១៩៧៩។ ទោះបីជា ចៅក្រមប្រឹក្សា **ហ្សង់ម៉ាក ឡាវែន៍** បានបង្ហាញថា យោងតាមឯកសារមន្ទីរ ស-២១ ចម្លើយសារភាពរបស់ **ប៉ង់** គឺចុះកាលបរិច្ឆេទដំបូងនៅថ្ងៃ២៨ ឧសភា ១៩៧៨ និងចុងក្រោយ នៅថ្ងៃទី២២ កក្កដា ១៩៧៨ ដែលកាលកំណត់នេះ គឺបញ្ជាក់ថា **ប៉ង់** ត្រូវបានចាប់ខ្លួនជាច្រើនខែមុនវៀតណាមចូល។ ករណីផ្សេងទៀត យោងតាមឯកសារមន្ទីរ ស-២១ តំណាងសហព្រះរាជអាជ្ញា **ដឺវ៉ាល់** បានបង្ហាញថា សាស្ត្រាចារ្យ **ឃួន ដារីង**ត្រូវបានចាប់ខ្លួនទៅមន្ទីរ ស-២១ នៅថ្ងៃទី២១ ធ្នូ ១៩៧៦ ចំណែកឯសក្ខីកម្មរបស់សាក្សី **សាឡុត បាន** លើកឡើងថា គាត់លែងបានជួបសាស្ត្រាចារ្យ **ឃួន ដារីង** នៅឆ្នាំ១៩៧៨ និងពុំបានរាយការណ៍ពីការបាត់ខ្លួននេះទៅពូរបស់ខ្លួនទេ ដោយសារតែកងទ័ពវៀតណាមបានខិតជិតមកដល់។ ព័ត៌មានទាំងនេះហាក់មិនស៊ីសង្វាក់ទៅនឹងពេលវេលា និងព្រឹត្តិការណ៍ ដែលសាក្សីលើកឡើងឡើយ "ការពឹងផ្អែកលើការចងចាំផ្ទាល់ខ្លួន ហាក់នាំមកនូវសក្ខីកម្មថ្មី"។

### ខ) សក្ខីកម្មរបស់សាក្សី ពាន ឃាន

មុនពេលកោះហៅសាក្សី **ពាន ឃាន** ចូលមកផ្តល់សក្ខីកម្ម អង្គជំនុំជម្រះសាលាដំបូងបានដឹកនាំនូវសវនាការអសាធារណៈមួយ ដើម្បីជជែកពិភាក្សាស្តីពីបញ្ហា ប្រឈមពាក់ព័ន្ធនឹងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងចំពោះសាក្សីរូបនេះ។ នៅពេលកិច្ចដំណើរការនីតិវិធីចាប់បន្តជាធម្មតាវិញ អង្គជំនុំជម្រះសាលាដំបូង បានតែងតាំងមេធាវីមួយរូបដល់សាក្សី **ពាន ឃាន** ដើម្បីជួយប្រឹក្សាយោបល់ផ្នែកច្បាប់ដល់រូបគាត់។

សាក្សី **ពាន ឃាន** មានអាយុ ៦២ឆ្នាំ មានមុខរបរជាជាងឈើ និងជាកសិករមួយរូប។ សាក្សីជាសមាជិកនៃជនជាតិភាគតិច *"ខ្មែត"* មានទីលំនៅបច្ចុប្បន្ន នៅភូមិរមន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ។ សាក្សី គឺជាអតីតនិរសារ (អ្នកនាំសារ) និងជាអង្គរក្សរបស់លោក **កុយ ធួន** (ដែលសាក្សីស្គាល់ថា **កុយ ឃួន**) និងក្រោយមកធ្វើការនៅមន្ទីរ ក-១។ សក្ខីកម្មរបស់សាក្សីបានសង្កត់ធ្ងន់លើបីចំណុចធំៗ ៖ ១) ការចូលរួមបដិវត្តន៍ និងទំនួលខុសត្រូវរបស់គាត់មុនពេលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាច ២)

ការចូលរួម ពាក់ព័ន្ធនៅពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាច និង ៣) ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

**១. ការចូលរួមបដិវត្តន៍ និងទំនួលខុសត្រូវមុនពេលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាច**

តំណាងសហព្រះរាជអាជ្ញាជាតិ **វើង ហ៊ាត់** បានចាប់ផ្តើមសាកសួរនូវសំណួរមួយចំនួនទៅកាន់សាក្សី **ពាន ឃាន** ពាក់ព័ន្ធនឹងការជ្រើសរើសឲ្យចូលបំពេញមុខងារក្នុងបក្សកុម្មុយនីស្តកម្ពុជា។ សាក្សីបានរៀបរាប់ថា គាត់បានចូលរួមចលនាបដិវត្តន៍ក្នុងឆ្នាំ១៩៦៦ នៅឃុំម៉ាលីក ស្រុកអណ្តូងមាស ខេត្តរតនគីរី នៅពេលនោះគាត់មានអាយុទើបតែ ១៦ឆ្នាំ ប៉ុណ្ណោះ។ នាពេលនោះ សមមិត្ត **ប៉ង់** និងសមមិត្ត **ធាត់** (ដែលជាប្រធានមន្ទីរនិរសារប្រចាំភូមិភាគឦសាន) បានណែនាំគាត់ឲ្យចូលបដិវត្តន៍ ដោយប្រាប់ថា ការចូលរួមបដិវត្តន៍ គឺមានគោលបំណងសំខាន់ដើម្បីរំដោះប្រទេសជាតិចេញពីពួកមូលធននិយម និងពួកសក្តិភូមិនិយម ក៏ដូចជារួមគ្នាបញ្ឈប់នូវការគៀបសង្កត់លើកសិករ។ គាត់ត្រូវតម្រូវឲ្យសរសេរប្រវត្តិរូបសង្ខេប ដែលទាក់ទងនឹងសាវតាផ្ទាល់ខ្លួនគ្រួសារ និងចំណេះដឹង។

***និរសារ (អ្នកនាំសារ) របស់អង្គការ*** ៖ បន្ទាប់ជាសមាជិកនៃសម្ព័ន្ធយុវជន សាក្សី **ពាន ឃាន** បានក្លាយជាអ្នកនាំសាររបស់ *"អង្គការ"* ប៉ុន្តែពេលនោះគាត់មិនបានស្គាល់ថ្នាក់ដឹកនាំណាម្នាក់ទេ ព្រោះគាត់ទទួលបញ្ជាត្រឹមតែពីអ្នកគ្រប់គ្រងផ្ទាល់ប៉ុណ្ណោះ។ សាក្សី **ពាន ឃាន** បានលើកឡើងថា *"មានគេប្រាប់ខ្ញុំអំពីអង្គការ ប៉ុន្តែខ្ញុំមិនបានដឹកដេញដោលសួរនាំអ្វីទេ"*។ គាត់បានរត់សំបុត្រទៅមករវាងស្រុកអណ្តូងមាស និងស្រុកវើនសៃ សំបុត្រត្រូវបានដាក់ក្នុងបំពង់ឬស្សីបិទជិត គាត់មិនបានដឹងអំពីអត្ថន័យនៅក្នុងសំបុត្រទាំងនោះទេ ព្រោះ *"គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យបើកមើលឡើយ"*។ សាក្សីបានចងចាំថា គាត់មិនត្រូវបានអនុញ្ញាតឲ្យទៅសួរសុខទុក្ខឪពុកម្តាយឡើយ និងបានបន្តថា សមាជិកដទៃទៀតដែលមានអាយុស្របាលគ្នាត្រូវបានទទួលរងនូវការដាក់ពិន័យ ប្រសិនបើ ពួកគេទៅផ្ទះដោយមិនមានការអនុញ្ញាត។

***ជាអង្គរក្សសមមិត្ត កុយ ធួន*** ៖ នៅប្រហែលជាឆ្នាំ១៩៦៨ និង ១៩៦៩[3] សាក្សីបានចាត់ឲ្យចូលបម្រើការងារជាអង្គរក្ស និងជានិរសាររបស់សមមិត្ត **កុយ ធួន** និងក្រោយមកទៅរស់នៅជាមួយប្រពន្ធរបស់ **កុយ ធួន** គឺលោកស្រី **យុន** ដែលនៅពេលនោះ សមមិត្ត **កុយ ធួន** បានក្លាយជាលេខាធិការភូមិភាគ៣០៤ (ជាភូមិភាគឧត្តរ[4]) ចំណែកឯប្រពន្ធរបស់គាត់ គឺជាប្រធានតំបន់។ សាក្សីបានបន្តទៀតថា ក្នុងកំឡុងឆ្នាំ ១៩៧៣ ឬ ១៩៧៤ គាត់បានទៅរស់នៅជាមួយលោកស្រី **យុន** នៅពេលដែលលោកស្រីបានប្តូរទៅស្រុក សណ្តាន់

ចំណែកឯ **កុយ ធួន** បានផ្លាស់ប្តូរទីតាំងទៅកាន់ស្រុកចំការលើ ខេត្តកំពង់ចាម។ សាក្សី **ពាន យាន** ក្នុងកំឡុងពេលនោះ គឺជាអ្នកនាំសារឲ្យអ្នកទាំងពីរ (ពីប្តីទៅប្រពន្ធ និងពីប្រពន្ធទៅប្តី)។

នៅចុងឆ្នាំ១៩៧៤ សមមិត្ត **កុយ ធួន** បានចាកចេញពីស្រុកចំការលើទៅកាន់សមរភូមិមុខ ដើម្បីដឹកនាំការប្រយុទ្ធវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ។ នាពេលនោះ សាក្សីបានរួមដំណើរជាមួយចៅហ្វាយនាយខ្លួន និងបានស្នាក់នៅនៅដំណាក់ស្តេច ស្រុកឧត្តុង្គ មុនការវាយប្រហារផ្តាច់ព្រ័តលើទីក្រុងភ្នំពេញ។ នៅពេលទីក្រុងភ្នំពេញ *"រំដោះ"* សាក្សីបានធ្វើដំណើរតាមចៅហ្វាយខ្លួនចូលមកកាន់ទីក្រុងភ្នំពេញ។

## ២. ជីវិតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា

យោងតាមសាក្សី **ពាន យាន** សមមិត្ត **កុយ ធួន** ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បន្ទាប់ពីខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ។ សាក្សីបានបន្តទៀតថា គាត់បានបម្រើការងារជានិរសារ និងជាអ្នកធ្វើម្ហូបឲ្យ **កុយ ធួន** នៅច្រាំងចម្រេះ[5] រហូតដល់ **កុយ ធួន** ត្រូវបានចាប់ខ្លួននាចុងឆ្នាំ ១៩៧៥ និង ១៩៧៦។ គាត់បានដឹងពី ការចាប់ខ្លួនចៅហ្វាយនាយខ្លួន តាមរយៈការស្តាប់តាមវិទ្យុ ដែលបានផ្សាយថា **កុយ ធួន** ត្រូវបានបញ្ជាឲ្យចាប់ខ្លួនដោយអង្គការ ដោយសារតែគាត់ជាជនក្បត់ និងចូលដៃជើងជាមួយចារកម្មអាមេរិក **ស៊ី.អាយ.អេ**។

សាក្សីបានបញ្ជាក់ថា សមមិត្ត **កុយ ធួន** ត្រូវបានឃុំឃាំងនៅកន្លែងមួយ ដែលមើលទៅហាក់ដូចជាសណ្ឋាគារ ដែលហ៊ុំព័ទ្ធដោយជញ្ជាំងបិទជិត មានចម្ងាយប្រហែលជា ៣០០ម៉ែត្រ ខាងត្បូងផ្ទះ **ប៉ុល ពត**។ មានពេលមួយតាមការបញ្ជារបស់ **ប៉ង់** សាក្សីបានយកមាន់មួយដែលចម្អិនស្រេចជូនដល់ **កុយ ធួន** បរិភោគ ក៏ប៉ុន្តែអ្នកទាំងពីរពុំបាននិយាយអ្វីច្រើនឡើយ ក្រៅតែពីការ សួរសុខទុក្ខប៉ុន្មានមាត់ប៉ុណ្ណោះ តែហាក់ដូចជារឿងចម្លែក ! ដែលសាក្សី **ពាន យាន** ពុំអាចចំណាំរូបថតរបស់ចៅហ្វាយនាយខ្លួន ដែលរូបនោះថតនៅឯមន្ទីរ ស-២១ និងបញ្ហាមួយទៀត នៅពេលដែលមានសំណួរថាតើសាក្សីបានដឹងពីការចាប់ខ្លួនបុគ្គលផ្សេងទៀតពីភូមិភាគឧត្តរ ឬពីក្រសួងពាណិជ្ជកម្ម? សាក្សីបានឆ្លើយបដិសេធ ប៉ុន្តែបែរជារៀបរាប់ថា គាត់បានឮពីការ រំលាយភូមិភាគឧត្តរ និងបង្កើតទៅជាភូមិភាគថ្មីផ្សេងទៀត ដូចនេះគាត់សន្និដ្ឋានថា នេះគឺជាការចាប់ខ្លួនអ្នកនៅក្រោមបង្គាប់របស់ **កុយ ធួន**។ ទោះបីយ៉ាងណា សាក្សីពុំបានបរិយាយឲ្យបានល្អិតល្អន់ក្នុងចំណុចនេះឡើយ។

ចំពោះសំណួរ ថាតើនរណាជា *"អង្គការ"* សាក្សី **ពាន យាន** បានឆ្លើយថា ពាក្យនេះគឺសំដៅទៅលើថ្នាក់ដឹកនាំបដិវត្តន៍ ហើយគាត់បន្ថែមថា គាត់ស្គាល់ **ប៉ុល ពត** គឺមុនខែមេសា ឆ្នាំ១៩៧៥។ នៅពេល **កុយ ធួន** ត្រូវបានចាប់ខ្លួន គាត់បានស្គាល់ថ្នាក់ដឹកនាំកំពូលៗ រួមមាន លោក **នួន ជា** លោក **អៀង សារី** និងលោក **សុន សេន** ដែលអ្នកទាំងនោះធ្វើការនៅមន្ទីរ ក-៣ ហៅថា "អ៊ំៗ"។

***ការបញ្ជូនទៅមន្ទីរ ក-១ ៖*** ពីរខែក្រោយពេលចាប់ខ្លួនសមមិត្ត **កុយ ធួន** សាក្សី **ពាន ឃាន** ត្រូវបានបញ្ជូនទៅកាន់មន្ទីរ ក-១ ដែលជាលំនៅដ្ឋានរបស់ **ប៉ុល ពត**។ សាក្សីបានរៀបរាប់ថា នៅមន្ទីរ ក-១ មានផ្ទះពីរខ្នងបែរមុខទៅទិសខាងកើត និងរុំព័ទ្ធទៅដោយរបងបិទជិត។ សាក្សីបានបន្តថា នៅពេលដែលគាត់ បានផ្លាស់ប្តូរទៅនៅមន្ទីរ ក-១ គាត់ទទួលបន្ទុកជាអ្នករកបន្លែបង្កា ដើម្បីទុកចម្អិនម្ហូបជូន *"អ៊ំ ប៉ុល"*។ គាត់បានរស់នៅទីនោះប្រហែលជាកន្លះឆ្នាំ បានឃើញជាប្រចាំ **ប៉ុល ពត** និង **ប៉ង់** និងឃើញលោក **នួន ជា** តែម្តងគត់។

សាក្សី **ពាន ឃាន** បានឲ្យដឹងថា ជាបន្ទាប់គាត់ត្រូវបានបញ្ជូនទៅតំបន់ *"ស្វាយមាស"* គឺនៅក្រោយពេលសមមិត្ត **ប៉ង់** ត្រូវបានបាត់ខ្លួន ដែលគាត់បានដឹងក្រោយមកថា អង្គការបានចាប់ខ្លួន **ប៉ង់**។

### គ. ទីស្នាក់ការកណ្តាលរបស់បក្សកុម្មុយនីស្តកម្ពុជា

នៅក្នុងសក្ខីកម្មរបស់ខ្លួន សាក្សីក៏បានផ្តល់នូវព័ត៌មានមួយចំនួនអំពីមន្ទីរ ក-៣ និងមន្ទីរ ក-៧ ។ គាត់បានរៀបរាប់ថា មន្ទីរ ក-៣ គឺជាទីស្នាក់ការកណ្តាលរបស់សមមិត្ត **ប៉ុល ពត** សមមិត្ត **ហែម** (ខៀវ សំផន) សមមិត្ត **អៀង សារី** និងសមមិត្ត **សុន សេន**។ ចំណែកឯមន្ទីរ ក-៧ សាក្សីពុំបានផ្តល់ព័ត៌មានណាមួយពីមុខងាររបស់វានោះទេ ក្រៅតែប្រាប់ពីទីតាំងតែប៉ុណ្ណោះ គឺនៅតាមបណ្តោយមាត់ទន្លេ។

សាក្សី **ពាន ឃាន** បានរៀបរាប់បន្ថែមថា ការិយាល័យ៨៧០ ជាទីបញ្ជាការនៃបក្សកុម្មុយនីស្តកម្ពុជា *"ជាទីស្នាក់ការកណ្តាល"*។ សក្ខីកម្មរបស់គាត់ក៏ដូចជាសក្ខីកម្មរបស់សាក្សីនានាបានលើកឡើងថា សមមិត្ត **ប៉ង់** គឺជាមនុស្សម្នាក់ដែលទទួលបន្ទុកលើការិយាល័យមួយនេះ ព្រមទាំង មន្ទីរនានា ដូចជា មន្ទីរ ក-១ មន្ទីរ ក-៣ និងមន្ទីរ ក-៧។ សាក្សី **ពាន ឃាន** បានឲ្យដឹងថា បើទោះជា **ប៉ង់** ពុំមានតួនាទីខ្ពស់ក៏ដោយ ក៏ក្នុងនាមជាជំនួយការ **ប៉ង់** អាចរាយការណ៍ដោយផ្ទាល់ទៅ **ប៉ុល ពត** តែក្រោយមក សមមិត្ត **លឺន** ជាអ្នកបន្តតំណែងនេះ បន្ទាប់ពី **ប៉ង់** ត្រូវបានចាប់ខ្លួន។

### ឃ. គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា

នៅក្នុងសក្ខីកម្មរបស់គាត់ សាក្សីបានឲ្យដឹងថា គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកដទៃទៀតដែលបានចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ដោយការជិះកង់មកដល់វត្តភ្នំនៅប្រហែលម៉ោង ៥ល្ងាច ប៉ុន្តែចៅហ្វាយនាយរបស់គាត់ **កុយ ធួន** បានមកដល់ទីក្រុងភ្នំពេញប្រហែលជា ៣ ឬ៤ម៉ោងមុន។ នៅពេលធ្វើដំណើរពីឧត្តុង្គទៅទីក្រុងភ្នំពេញ សាក្សីបានប្រាប់ថា គាត់បានឃើញប្រជាជនដើរជាជួរយ៉ាងវែងអន្លាយចេញពីទីក្រុងភ្នំពេញ អ្នកខ្លះធ្វើដំណើរដោយយានជំនិះ តែភាគច្រើនធ្វើដំណើរដោយថ្មើរជើង។ ផ្ទុយទៅវិញ គាត់បានលើកឡើងថា នៅជុំវិញបរិវេណវត្តភ្នំមានសភាពស្ងាត់ជ្រងំ នៅពេល

គាត់ទៅវិញ។ ទោះបីជាយ៉ាងណាគាត់មិនបានដឹងពីការជម្លៀសប្រជាជននោះទេ ព្រោះខ្មែរក្រហមថា ធ្វើការបោសសំអាតសត្រូវពីទីក្រុងតែប៉ុណ្ណោះ។

***ការលុបបំបាត់សាសនា ៖*** សាក្សីបានឲ្យដឹងថា មុនឆ្នាំ១៩៧៥ មនុស្សគ្រប់រូប រួមទាំង ជនជាតិដើមភាគតិច អាចប្រតិបត្តិនូវជំនឿសាសនាដោយសេរី។ តាមទំនៀមទំលាប់ ពុទ្ធបរិស័ទប្រារព្ធពិធីនៅទីវត្តអារ៉ាម និង អភវន្ទនាការចំពោះព្រះសង្ឃ ប៉ុន្តែក្រោយឆ្នាំ១៩៧៥ វត្តអារ៉ាមត្រូវបានបិទ និងព្រះសង្ឃត្រូវបានបង្ខំឲ្យលាចាកសិក្ខាបទ។

***សត្រូវរបស់អង្គការ ៖*** សហព្រះរាជអាជ្ញាបានស្វះស្វែងរកការស្រាយបំភ្លឺពីសាក្សី ថាតើនរណាខ្លះជាសត្រូវរបស់បក្សកម្ពុជាប្រជាធិបតេយ្យ។ តាមសក្ខីកម្មរបស់សាក្សី សត្រូវរបស់អង្គការ គឺសំដៅទៅលើ មន្ត្រីរដ្ឋការ និងទាហានរបស់ **លន់ ណុល** ព្រមទាំង **លន់ ណុល** ខ្លួនឯងផ្ទាល់ ត្រូវបានហៅថា “ជាសត្រូវស្លាប់រស់”។ សាក្សីបានបន្ថែមថា បក្សកុម្មុយនីស្តកម្ពុជាក៏បានចាត់ទុក ខ្សែរាជវង្ស ភ្នាក់ងារ ស៊ី.អាយ.អេ ភ្នាក់ងារ កា.ស្សេ.បេ និងជនជាតិយួន ថាជាសត្រូវផងដែរ ប្រសិនបើចាប់បាន អ្នកទាំងនោះត្រូវតែកម្ទេច។

## III. **បញ្ហាច្បាប់ និងនីតិវិធី**

ដំណើរការនីតិវិធីនាសប្តាហ៍នេះ បញ្ហាច្បាប់និងនីតិវិធីពុំសូវចោទជាចំណោទខ្លាំងនោះទេ។ មេធាវីការពារក្តីលោក **នួន ជា** បានស្នើសុំឲ្យមានសវនាការជាអសាធារណៈ ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមលើការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺមុនពេលសាក្សី **ពាន ឃាន** ឡើងផ្តល់សក្ខីកម្ម។ ចំណែកឯ មេធាវីការពារក្តីលោក **អៀង សារី** បានលើកឡើងពីបញ្ហាទទួលយកឯកសារ (ដែលជាសេចក្តីសង្ខេបនៃបទសម្ភាសន៍) ធ្វើជាភស្តុតាង។ បញ្ហាដែលរសើប គឺថា មេធាវីការពារក្តីលោក **នួន ជា** បានចោទប្រកាន់ថា ចៅក្រមប្រឹក្សា **ស៊ីលវ៉ាវ៍ ខាតវ៉ាយថ៍** បានសម្តែងនូវកាយវិការពុំសមរម្យក្នុងកំឡុងពេលដំណើរការនីតិវិធី និង បានដាក់សំណើសុំឲ្យមានការដាក់ពិន័យ។ រីឯបញ្ហាចុងក្រោយ គឺជាបញ្ហាទាក់ទងនឹងការប្រើប្រាស់ចម្លើយ សារភាពបានមកពីការធ្វើទារុណកម្ម។

### ក. សិទ្ធិរបស់សាក្សីទទួលបាននូវការការពារពីការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង

កាលពីពីរសប្តាហ៍មុន ចំពោះករណីរបស់សាក្សី **សូត្រ តឿង**[6] ត្រូវបានមេធាវី **អែនទ្រូ អ៊ីនូហ្ស៊ី** ដែលជាមេធាវីការពារក្តីលោក **នួន ជា** បានលើកម្តងហើយពីបញ្ហាមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ចំណែក

ឯសប្តាហ៍នេះ លោកមេធាវីបានលើកម្តងទៀតចំពោះសាក្សីថ្មី "**ពាន ឃាន**" និងស្នើសុំឲ្យមាន សវនាការជាអសាធារណៈ ដើម្បីពិភាក្សាពីបញ្ហានេះ។ មេធាវីបន្តថា ក្រោយពីពិនិត្យឯកសារមួយចំនួន នៅក្នុងសំណុំរឿង គាត់បានសង្កេតឃើញថា ឯកសារទាំងនោះហាក់ដាក់ពិរុទ្ធភាពទៅលើសាក្សី។ មេធាវីបន្ថែមថា គាត់រីករាយក្នុងការផ្តល់សេចក្តីពន្យល់អធិប្បាយលម្អិតនៅក្នុងសវនាការជាអសាធារណៈ។

ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបានលើកឡើងថា វាពុំមានករណីចាំបាច់ដែលតម្រូវឲ្យមានសវនាការជាអសាធារណៈក្នុងការពិភាក្សាលើបញ្ហានេះទេ ព្រោះរបាយការណ៍របស់សាក្សីរូបនេះត្រូវបានផ្តល់ដល់គ្រប់ភាគីចាប់តាំងពីឆ្នាំ២០០៧មកម្ល៉េះ។ តំណាងសហព្រះរាជអាជ្ញា **ថារីក អ៊ាប់ឌុលហាក់** បានស្នើដល់អង្គជំនុំជម្រះថា ការប្រាប់ពីសិទ្ធិ និងទុកពេលឲ្យសាក្សីសមរម្យពិគ្រោះយោបល់ជាមួយមេធាវី គឺជា ករណីចាំបាច់។ តំណាងសហព្រះរាជអាជ្ញាបានរំឭកដល់គ្រប់ភាគីថា នាសប្តាហ៍មុន លោកស្រីចៅក្រម **ខាតរ៉ាយច៍** បានជូនព័ត៌មានយ៉ាងជាក់លាក់អំពីសំណើសុំនានា ភាគីគួរធ្វើសំណើជាលាយលក្ខណ៍អក្សរ និងដាក់ជូន អង្គជំនុំជម្រះឲ្យបានជាមុន។ ចំណែកឯ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី **អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត** បានសម្តែងការគាំទ្រចំពោះសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា និងបានជម្រុញឲ្យអង្គជំនុំជម្រះនៅ តែរក្សាកាលានុវត្តភាពនៃដំណើរការនីតិវិធី។

បន្ទាប់ពីស្តាប់នូវអំណះអំណាងគ្រប់ភាគី អង្គជំនុំជម្រះបានសម្រេចថា សវនាការនឹងធ្វើជាអសាធារណៈ ដើម្បីពិភាក្សាពីបញ្ហារបស់មេធាវីការពារក្តីលោក **នួន ជា**។ បន្ទាប់ពីកិច្ចពិភាក្សាជាអសាធារណៈ ការស្តាប់សក្ខីកម្មរបស់សាក្សី **ពាន ឃាន** ត្រូវបានចាប់ផ្តើម និងបានតែងតាំងមេធាវីប្រឹក្សាមួយរូបដល់សាក្សីក្នុងកំឡុងពេលដែលគាត់ផ្តល់សក្ខីកម្ម យោងតាមវិធាន ២៨(៩)។

### ខ. បញ្ហានៃការទទួលយកឯកសារសង្ខេបជាភស្តុតាង

មេធាវី **ម៉ៃខល កាណាវ៉ាស** ដែលជាមេធាវីការពារក្តីលោក **អៀង សារី** បានបដិសេធយ៉ាងដាច់អហង្ការចំពោះការទទួលយកឯកសារសង្ខេបពីបទសម្ភាសន៍របស់សាក្សី **ពាន ឃាន** ដែលរៀបចំដោយលោក **ស្ទីវ ហេឌឺ** មេធាវី **កាណាវ៉ាស** បានលើកទឡ្ហីករណ៍ថា ការធ្វើបែបនេះពុំអាចទទួលយកបានទេ ព្រោះថាពុំមានខ្សែអាត់សម្លេងដើម្បីបញ្ជាក់ពីកិច្ចសម្ភាសន៍នោះ ថាតើមានសុក្រឹត្យភាពឬយ៉ាងណា។ រីឯមេធាវី **គង់ សំអុន** ដែលជាមេធាវីការពារក្តីលោក **ខៀវ សំផន** បានគាំទ្រនូវសេចក្តីជំទាស់នេះ ហើយបន្ថែមថា ឯកសារសង្ខេបពុំអាចប្រើប្រាស់បញ្ជាក់ ឬដេញដោលលើសក្ខីកម្មសាក្សីបានទេ ព្រោះពុំអាចបង្ហាញពីតឹកតាងថា ឯកសារនោះទទួលបានពីសាក្សី និងមានប្រភពដែលអាចផ្ទៀងផ្ទាត់បាន។ លោកមេធាវីបន្តថា ភាគីអាចសួរដេញដោលសាក្សីដោយផ្ទាល់ ជាជាងយោងទៅលើឯកសារសង្ខេប ព្រោះថា

សាក្សីបានមកនៅចំពោះមុខហើយ។ ចំណែកឯមេធាវី **អ៊ីនូហ្សី** បានស្នើថា គួរតែកោះហៅលោក **ស្ទីវ ហេឌី** មកផ្តល់សក្ខីកម្មផងដែរ។

សហព្រះរាជអាជ្ញាបានបដិសេធថា សំណើរបស់មេធាវី **កាណាវ៉ាស** គឺពុំមានមូលដ្ឋានច្បាប់នោះទេ និងពុំមានបទបញ្ញត្តិណាមួយនៃវិធាននៃផ្ទៃក្នុង ហាមឃាត់ការប្រើប្រាស់ឯកសារសង្ខេបជាសភស្តុតាងនោះដែរ។ គាត់បានដកស្រង់ករណីលោក **មីឡូទូនូវិក**[7] (០១ កញ្ញា ២០០៦) និងករណីលោក **ហ្គោតូវីណា**[8] (១១ មេសា ២០១១) ដោយលើកឡើងថា ឯកសារសង្ខេបដែលរៀបចំដោយតតីយជន គឺអាចទទួលយកជាភស្តុតាងបាន ព្រោះឯកសារទាំងនោះបានបញ្ជាក់ពីកម្រិតអប្បរមាពីសញ្ញាណនៃការទទួលខុសត្រូវហើយ។ម្យ៉ាងទៀត វាពិតជាមានសារៈសំខាន់ណាស់ ដែលរាល់ឯកសារពាក់ព័ន្ធនឹងសាក្សីគួរត្រូវបានដាក់ជូនអង្គជំនុំជម្រះពិចារណា។ សហព្រះរាជអាជ្ញាក្រើនរំឭកក្រុមមេធាវីការពារក្តីថា ពួកគេមានឱកាសសួរដេញដោលសាក្សីពីរបាយការណ៍ទាំងនេះ។ មេធាវី **ស៊ីម៉ុនណូហ្វត** បានគាំទ្រចំពោះអំណះអំណាងរបស់សហព្រះរាជអាជ្ញា ព្រមទាំងបញ្ជាក់ពីភាពភ័ន្តច្រលំរវាងការដាក់ឯកសារ និងតម្លៃនៃភស្តុតាង ៖ គឺពុំមែនដោយសារតែឯកសារសង្ខេប ទើបឯកសារនោះពុំអាចទទួលយកបានទេ។

ជាការឆ្លើយតប មេធាវី **កាណាវ៉ាស** បានលើកឡើងថា សេចក្តីជំទាស់របស់ខ្លួន គឺផ្អែកទៅលើមូលដ្ឋានថា ដោយសារតែពុំមានខ្សែអាត់សម្លេងក្នុងការផ្ទៀងផ្ទាត់ ថាតើឯកសារសង្ខេបនោះទទួលបានដោយរបៀបណា។ មេធាវីបន្តថា ក្នុងនាមជាមេធាវី ខ្លួនបានយល់យ៉ាងច្បាស់ពីភាពងាយស្រួលក្នុងការរៀបចំសាក្សី ឬណែនាំពីរបៀបនៃការឆ្លើយតបនឹងសំណួរ។ ជាងនេះទៀត មេធាវីសង្កត់ធ្ងន់អំពីការបង្ហាញឯកសារក្នុងការរំឭកការចងចាំ គាត់បានចោទជាសំណួរថា បើការសន្ទនានោះត្រូវបានរៀបចំជាមុន តើធ្វើដូចម្តេចអាចផ្ទៀងផ្ទាត់បាន។ នៅក្នុងរបាយការណ៍សង្ខេបដែលរៀបចំដោយលោក **ស្ទីវ ហេឌី** គឺធ្វើយ៉ាងណាឲ្យមានការចោទប្រកាន់ដល់ជនជាប់ចោទ និងដាក់ពិរុទ្ធភាពលើពួកគេតែប៉ុណ្ណោះ ដែលនេះពុំយុត្តិធម៌ទេ។

ចំពោះការដកស្រង់យុត្តិសាស្ត្រនានា មេធាវីបានតវ៉ាថា នៅពេលខ្លួនលើកឡើងពីការអនុវត្តន៍ និងយុត្តិសាស្ត្រនានាពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយោហ្គោស្លាវី អង្គជំនុំជម្រះបានរំឭកថា នៅទីនេះពុំមែនជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយោហ្គោស្លាវីឡើយ តែឥឡូវសហព្រះរាជអាជ្ញាក៏បានពឹងផ្អែកលើយុត្តិសាស្ត្រទាំងនោះដែរ ដូច្នេះត្រូវអនុវត្ត "គោលការណ៍តែមួយ"។ មេធាវីបានលើកពីគោលសំខាន់ៗនៃមូលដ្ឋានខុសគ្នារវាងតុលាការទាំងពីរ ៖ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយោហ្គោស្លាវី មេធាវីការពារក្តី គឺមានសិទ្ធិសួរដេញដោលសាក្សីដោយសំណួរនាំមុខ ប៉ុន្តែនៅ អ.វ.ត.ក មេធាវីការពារក្តីមិនអនុញ្ញាតឲ្យធ្វើដូច្នោះទេ។

អំណះអំណាងជាបន្តបន្ទាប់នៃបញ្ហានេះពុំត្រូវបានដឹងឡើយ ដោយសារតែអង្គជំនុំជម្រះបានសម្រេចធ្វើសវនាការជាអសាធារណៈ។ នៅពេលសវនាការប្រព្រឹត្តទៅជាប្រក្រតីឡើងវិញ សេចក្តីសម្រេច អំពីឯកសារសង្ខេបត្រូវបានទទួលយកជាភស្តុតាង។

### គ. ការចោទប្រកាន់ពីអកប្បកិរិយាពុំសមរម្យរបស់ចៅក្រម

នៅថ្ងៃពុធ មេធាវី **អ៊ីនូហ្ស៊ី** បានព្យាយាមដាក់សំណើមួយជូនអង្គជំនុំជម្រះ ស្នើសុំឲ្យមានការដាក់ពិន័យលើលោកស្រីចៅក្រម **ខាតវ៉ាយថ៍** ចំពោះការសម្តែងកាយវិការពុំសមរម្យនៅក្នុងពេលសវនាការ។ មេធាវីបានអះអាងថា កាលពីថ្ងៃច័ន្ទ នៅពេលមេធាវី **ផេស្តមេន** បានកំពុងសួរដេញដោលសាក្សី **សាឡុតបាន** ពាក់ព័ន្ធបញ្ហានៃការជ្រែតជ្រៀកផ្នែកនយោបាយ ភ្លាមៗនោះលោកមេធាវីបានសង្កេតឃើញថា លោកស្រីចៅក្រម **ខាតវ៉ាយថ៍** "គ្រវីក្បាល និងធ្វើមាត់មួបៗ..."។ មេធាវីបន្តថា នេះគឺជាកាយវិការមួយពុំសមរម្យចំពោះមេធាវីការពារក្តីលោក **នួន ជា** "ដែលហាក់បញ្ចេញនូវភាពលម្អៀង"។ មេធាវី **អ៊ីនូហ្ស៊ី** បានឲ្យដឹងថា ដោយកង្វះយុត្តិសាស្ត្រអន្តរជាតិក្នុងការគាំទ្រសំណើខ្លួន គាត់បែរជាយោងទៅបទចម្រៀង មួយបទរបស់ក្រុមតន្ត្រីអាមេរិកាំង N.W.A មានចំណងជើងថា "បញ្ចេញមតិ Express Yourself" ដកស្រង់ខ្លឹមសារថា "អ្នកខ្លះអាចបើកក្បាលមីក្រូដើម្បីនិយាយ" ដែលប្រហែលជាមានចេតនាចង់ទាក់ទាញចំណាប់អារម្មណ៍របស់សាធារណជន។ មូលហេតុដែលមេធាវីដកស្រង់ក្រុមដន្ត្រី **ដុកទ័រ ទ្រេ** "គឺដើម្បីបញ្ជាក់ពីអកប្បកិរិយារបស់លោកស្រីចៅក្រម" ដែលថា "លោកស្រីចៅក្រមគួររៀបចំអាកប្បកិរិយារបស់ខ្លួនឲ្យបានសមរម្យ បង្ហាញនូវសមត្ថភាពពេញលេញ និងក្នុងនាមវិជ្ជាជីវៈ ជាជាងសម្តែងកាយវិការណាមួយ ដែលបង្ហាញពីភាពអនាគតិចំពោះភាគី" ព្រោះករណីនេះ អាចទុកជាកំណត់ត្រាតុលាការ។ មេធាវីស្នើសុំបន្ថែមថា អង្គជំនុំជម្រះគួរធ្វើការ ណែនាំដល់លោកស្រីចៅក្រម **ខាតវ៉ាយថ៍** ឲ្យបញ្ឈប់កាយវិការនេះ ទាំងនៅពេលបច្ចុប្បន្ន និងអនាគត។

តំណាងសហព្រះរាជអាជ្ញា **វាំងសង់ វ៉ាយដ៍ ដេស្មាឯល** បានថ្លែងថា កំណត់សម្គាល់របស់មេធាវី **អ៊ីនូហ្ស៊ី** គឺពុំសមហេតុផលទាល់តែសោះ។ ក្រុមមេធាវីការពារក្តីលោក **នួន ជា** កំពុងព្យាយាមបង្ខូចកិត្តិយសរបស់ចៅក្រម **ខាតវ៉ាយថ៍** និងទាមទារថា ខ្លួនជាជនរងគ្រោះ។ តំណាងសហព្រះរាជ្ញាបានជម្រុញឲ្យតុលាការ ធ្វើការដាក់ទណ្ឌកម្មដល់ក្រុមមេធាវីការពារក្តីលោក **នួន ជា** ចំពោះការលើកឡើងពុំសមរម្យនេះ។

បន្ទាប់ពីកិច្ចពិភាក្សាពិចារណាលើសំណើនេះ (ចៅក្រម **ខាតវ៉ាយថ៍** ពុំស្ថិតក្នុងកិច្ចពិភាក្សា) អង្គជំនុំជម្រះបានសម្រេចច្រានចោលសំណើនោះ ដោយផ្តល់ហេតុផលថា "សំណើរបស់មេធាវីការពារក្តីលោក **នួន**

ជា ពុំមានមូលដ្ឋានទាល់តែសោះ គ្រាន់តែនិយាយបង្ហាញការចោទប្រកាន់ជាសាធារណៈនៅ ចំពោះមុខអង្គសវនាការតែប៉ុណ្ណោះ”។

**ឃ. ការប្រើប្រាស់ឯកសារដែលទទួលបានតាមរយៈការធ្វើទារុណកម្ម**

កាលពីថ្ងៃច័ន្ទ នៅពេលសួរដេញដោលសាក្សី **សាឡុត បាន** មេធាវី **កាណាវ៉ាស** បានសង្កត់ធ្ងន់ទៅលើចម្លើយសារភាពរបស់ **កុយ ធួន** បានមកពីមន្ទីរ ស-២១។ ការប្រើប្រាស់ឯកសារដែលទទួលបានពីការធ្វើទារុណកម្ម អង្គជំនុំជម្រះបានសម្រេចរួចហើយថា ឯកសារទាំងនោះ មិនអាចយកមកប្រើប្រាស់ជាភស្តុតាងនៅក្នុងសំណុំរឿងនេះបានទេ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានរំលឹកដល់មេធាវីថា គឺអាចត្រឹមតែយោងទៅរកកាលបរិច្ឆេទ ឬពេលវេលានៃការចាប់ខ្លួនតែប៉ុណ្ណោះ។ ទោះបីជាមេធាវី **កាណាវ៉ាស** ទទួលបានការណែនាំយ៉ាងណាក៏ដោយ ក៏ខ្សែសង្វាក់នៃសំណួររបស់គាត់នៅតែសំដៅដល់អត្ថន័យនៃចម្លើយសារភាពរបស់ **កុយ ធួន** ដែលចំណុចនេះ អង្គជំនុំជម្រះបានធ្វើអន្តរាគមន៍ និងបង្គាប់ឲ្យសាក្សីមិនឆ្លើយតបសំណួរ។

ផ្ទុយទៅវិញ នៅពេលចៅក្រម **ឡាវែរ៍** បានយោងទៅលើចម្លើយសារភាពនៃមន្ទីរ ស-២១ គឺសំដៅតែទៅលើកាលបរិច្ឆេទប៉ុណ្ណោះ ព្រោះព្រឹត្តការណ៍ដែលសាក្សី **សាឡុត បាន** បានលើកឡើងហាក់ពុំស៊ីសង្វាក់ទៅនឹងកាលបរិច្ឆេទ ដែលមាននៅក្នុងចម្លើយសារភាព។ ការអនុវត្តន៍នេះ គឺសម្រេចតែទៅតាមការយល់ឃើញរបស់អង្គជំនុំជម្រះ ថាតើការប្រើប្រាស់ និងសេចក្តីយោងកម្រិតណាទៅលើចម្លើយសារភាព។

**ង. បញ្ជីឯកសាររបស់ភាគី**

នៅក្នុងរយៈពេលសវនាការពីរថ្ងៃនាសប្តាហ៍នេះ ក្រុមមេធាវីការពារក្តីលោក **នួន ជា** បានតវ៉ានឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ តម្រូវឲ្យភាគីបញ្ចូលឯកសារភស្តុតាងទាំងឡាយ ដែលខ្លួនមានបំណងនឹងយកមកប្រើប្រាស់នៅក្នុងតុលាការ ដាក់ក្នុងបញ្ជីឯកសាររបស់ខ្លួន និងដាក់ជូនអង្គជំនុំជម្រះពិនិត្យជាមុន។ ទោះបីជា អង្គជំនុំជម្រះតែងរំលឹកដល់ភាគីម្តងហើយម្តងទៀត ក៏មេធាវី **ផេស្តមេន** នៅតែប៉ុនប៉ងសួរដេញដោលសាក្សី **សាឡុត បាន** ទៅលើឯកសារដែលមិនមាននៅក្នុងបញ្ជីរបស់ពួកគេ ដោយហេតុនេះអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យបន្តឡើយ។ មេធាវី **ផេស្តមេន** បានបកស្រាយថា ឯកសារទាំងនេះ មិនចាំបាច់បញ្ចូលទៅក្នុងបញ្ជីឯកសារទេ និងបន្តថា គាត់ពុំមានបំណងចង់ដាក់ឯកសារនេះជាភស្តុតាងនោះទេ គឺគ្រាន់តែប្រើប្រាស់ ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់របស់សាក្សីតែប៉ុណ្ណោះ។ មេធាវីបន្ថែមថា គាត់នឹងដាក់សំណើ

បដិសេធនេះជាលាយលក្ខអក្សរជូនអង្គជំនុំជម្រះតាមក្រោយ។ ***គួរកត់សម្គាល់*** ការធ្វើបែបនេះ មេធាវី **ផៃស្តមេន** បានធ្លាប់លើកឡើងហើយ កាលពីរទៅបីសប្តាហ៍មុន ។

## IV. ការគ្រប់គ្រងដំណើរការជំនុំជម្រះ

ដំណើរការនីតិវិធីសវនាការនាសប្តាហ៍នេះ បញ្ហាចោទខ្លាំង គឺជាការវិវត្តន៍ និងការគ្រប់គ្រងពេលវេលានៃសវនាការ។ តួយ៉ាង ដូចជាការដកស្រង់អត្ថន័យនៃក្រុមតន្ត្រីអាមេរិកាំង នៅពេលដែលអវត្តមាននៃយុត្តិសាស្ត្រអន្តរជាតិ លើកឡើងដោយក្រុមមេធាវីការពារក្តីលោក **នួន ជា** ដែលនេះហាក់ដូចជារឿងប្រឡោមលោកមួយ និងកំពុងធ្វើការសាកល្បងពីភាពអត់ធ្មត់របស់អង្គជំនុំជម្រះ ថាតើការលើកឡើងក្រៅព្រំដែនច្បាប់ត្រូវបានអនុញ្ញាត។

### ក. ការគ្រប់គ្រងពេលវេលា

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានខិតខំប្រឹងប្រែងផ្តល់ ពេលវេលាគ្រប់គ្រាន់ដល់គ្រប់ភាគី ក្នុងការសួរដេញដោលសាក្សី ដែលនេះប្រហែលជាការខិតជិតមកដល់នៃវិសម្មកាល និងភាពចាំបាច់បន្ទាន់បង្ខំនានា រួមមាន ការធ្វើសវនាការជាអសាធារណៈ ដែលពិភាក្សាពីបញ្ហាប្រឈមរបស់សាក្សី **ពាន ឃាន** ក្នុងការមិនធ្វើសក្ខីកម្មដាក់បន្ទុកលើខ្លួនឯង។

ប្រធានអង្គជំនុំជម្រះ **និល ណុន** បានព្យាយាមធ្វើយ៉ាងណាពន្លឿននីតិវិធី ដោយក្រើនរំលឹកដល់ក្រុមការពារក្តីលោក **ខៀវ សំផន** ធ្វើយ៉ាងណាប្រើប្រាស់ពេលវេលាឲ្យ មានប្រសិទ្ធភាព និងសួរសំណួរដែលពាក់ព័ន្ធ នៅពេលដែលមេធាវី **គង់ សំអុន** បានចោទសួរសាក្សីពីប្រភេទ និងទីតាំងទីបញ្ជាការរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលហាក់ដូចជាមិនបង្ហាញពីបន្ទុក និងភាពពាក់ព័ន្ធទៅនឹងអង្គហេតុនោះឡើយ។

ចំពោះការដេញដោលសាក្សី **ពាន ឃាន** អង្គជំនុំជម្រះបានផ្តល់ពេលវេលាប្រហែលជា បីម៉ោង ដល់សហព្រះរាជអាជ្ញាក្នុងការសួរដេញដោលសាក្សីរូបនេះ។ ក្នុងការសួរដេញដោល សក្ខីកម្មរបស់សាក្សីបានលេចចេញនូវព័ត៌មានថ្មី ដែលពុំមាននៅក្នុងរបាយការណ៍របស់សហចៅក្រមស៊ើបអង្កេត ជាពិសេស ទំនាក់ទំនងរបស់សាក្សីជាមួយ **កុយ ធួន** និង **ប៉ង់** ព្រមទាំងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ហេតុដូចនេះ តំណាងសហព្រះរាជអជ្ញា **អាប់ឌុលហាក់** បានស្នើសុំពេលវេលាប្រហែលជាពីរម៉ោងបន្ថែមទៀត។ តាមសំណើនេះ អង្គជំនុំជម្រះបានសម្រេចផ្តល់ពេលវេលាដល់សហព្រះរាជអាជ្ញាអាចបន្តរហូតពេញមួយ

ព្រឹកថ្ងៃព្រហស្បតិ៍ និងបានប្រកាសថា នឹងមានសវនាការនៅថ្ងៃសុក្រនាសប្តាហ៍នេះ។ ទោះជាយ៉ាងណា ការបម្រុងទុកនេះត្រូវបានផ្លាស់ប្តូរវិញ នៅពេលសាក្សីមានអក្ការៈមិនស្រួលខ្លួន។ នៅថ្ងៃព្រហស្បតិ៍ នាវគ្គទី១នៃសវនាការ អង្គជំនុំជម្រះបានឲ្យដឹងថា សាក្សីពុំមានសុខភាពគាប់ប្រសើរ និងបានសួរបញ្ជាក់សាក្សីតើគាត់អាចបន្តសក្ខីកម្មបានទេ? សាក្សី **ពាន ឃាន** ឆ្លើយតបថា គាត់ពិតជាមានបញ្ហាសុខភាព ប៉ុន្តែគាត់អាចបន្តសក្ខីកម្មខ្លួនបាន។ ជាក់ស្តែង បញ្ហាសុខភាពរបស់គាត់កាន់តែធ្ងន់ធ្ងរ ជាលទ្ធផល អង្គជំនុំជម្រះបានប្រកាសម្រាកមុនពេលកំណត់ ព្រមទាំងប្រកាសថា សវនាការនឹងចាប់ផ្តើមឡើងវិញ បន្ទាប់ពីវិសម្មកាលនៅថ្ងៃទី ១៧ ឧសភា ២០១២ ។

**ខ. វត្តមាន**

ដូចសប្តាហ៍មុនៗ ជនជាប់ចោទទាំងបីរូបមានវត្តមាននៅពេលចាប់ផ្តើមសវនាការតែប៉ុណ្ណោះ។ លោក **អៀង សារី** តែងតែស្នើសុំចាកចេញ នៅចុងបញ្ចប់នៃវគ្គទី១ សុំទៅតាមដានពីចម្ងាយពីបន្ទប់រង់ចាំខាងក្រោម ដោយសារបញ្ហាសុខភាពរបស់ខ្លួន។ ចំណែកឯ **នួន ជា** នៅថ្ងៃច័ន្ទ បានស្នើសុំចាកចេញនៅចុងបញ្ចប់វគ្គទី២ ទៅតាមដានពីចម្ងាយពីបន្ទប់រង់ចាំពេញមួយថ្ងៃរសៀល និងវត្តមានរបស់គាត់នៅថ្ងៃពុធក៏ដូចគ្នាដែរ។ រីឯលោក **ខៀវ សំផន** គឺជាមនុស្សតែម្នាក់ពុំស្នើសុំចាកចេញពីបន្ទប់សវនាការទេ ពេញមួយសប្តាហ៍នេះ ផ្ទុយទៅវិញ បែរជាអវត្តមានមេធាវីអន្តរជាតិរបស់គាត់ទៅវិញ គឺមានតែមេធាវីជាតិ **គង់ សំអុន** ដែលមានវត្តមាននៅក្នុងតុលាការ។

**វត្តមានសាធារណៈជន ៖** និសិត្សប្រមាណ ៨០០ នាក់ និងប្រជាជនមកពីតាមខេត្តប្រមាណជា ៨០០ នាក់ដែរ បានចូលរួមសវនាការនាសប្តាហ៍នេះ។ នៅថ្ងៃច័ន្ទ ប្រជាជនប្រហែលជា ៥០០នាក់ មកពីខេត្តកំពុងចាម បានតាមដានសវនាការនាពេលព្រឹក នៅថ្ងៃទី៣០ មេសា ២០១២ ចំណែកឯនៅពេលរសៀល សិស្សមកពីអនុវិទ្យាល័យ**ហ៊ុនសែនប៊ុនរ៉ានីអរុណវត្តី**។ នៅថ្ងៃទីពីរ ប្រជាជនជាង ៣០០នាក់ មកពីស្រុកបសេ្សិត ខេត្តកំពង់ស្ពឺ បានចូលរួមសវនាការនាពេលព្រឹក និងសិស្សជាង ៣០០នាក់ មកពីវិទ្យាល័យថ្នល់ទទឹង ខេត្តកណ្តាល បានចូលរួមសវនាការនាថ្ងៃរសៀល។ នៅថ្ងៃទី៣ សិស្សប្រមាណ ៣០០នាក់ មកពីវិទ្យាល័យ**សម្តេចតេជោហ៊ុនសែនស្នួង** ខេត្តកំពុងចាម បានចូលរួមសវនាការនាពេលព្រឹក។

## គ. ការគ្រប់គ្រងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | ការសម្រាក ពេលព្រឹក | អាហារ ថ្ងៃត្រង់ | ការសម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោង សរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ៣០/០៤/១២ | ៩.០១ | ១០.៤៨-១១.០៥ | ១២.០២-១៣.៣០ | ១៤.៣៤-១៥.០៣ | ១៦.០២ | ៤ ម៉ោង និង៤៧ នាទី |
| ថ្ងៃពុធ ០២/០៥/១២ | ៩.០៧ | ១០.២៩ សវនាការជាអសាធារណៈ | ១៣.៣៣- សវនាការជាអសាធារណៈ | ១៤.៤០-១៥.០១ | ១៦.០៣ | ៣ ម៉ោង និង៣២ នាទី |
| ថ្ងៃព្រហស្បតិ៍ ០៣/០៥/១២ | ៩.០១ | ១០.៣២-១១.១២ | - | - | ១១.១៨ | ១ ម៉ោង និង ៣៧ នាទី |

ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ ៖ ៣ ម៉ោង និង ១៩ នាទី

ចំនួនម៉ោងសរុបក្នុងសប្តាហ៍នោះ ៖ ៩ ម៉ោង និង ៥៦ នាទី

ចំនួនសរុបនៃ ម៉ោង ថ្ងៃ និង សប្តាហ៍ ៖ ២៥៤ ម៉ោង និង ១៥ នាទី

៥៩ ថ្ងៃ និង ១៧ សប្តាហ៍

1 ភាពមិនច្បាស់លាស់ចំពោះការសរសេរប្រកបឈ្មោះ ‟ជាម″។ ក្នុងគោលបំណងចងក្រងរបាយការណ៍នេះ ឈ្មោះមួយនេះត្រូវបានប្រកបតាមសូរសំនៀងអាន។

2 ទោះបីជាមានសំណូមពរ ឲ្យមានការបំភ្លឺ និង បញ្ជាក់ឲ្យច្បាស់ ថាតើឈ្មោះ ‟កុយ ធួន″ និង បុគ្គលដែលគាត់ហៅថា ‟កុយ ឃួន″ ជាបុគ្គលតែមួយ សាក្សី លោក ពាន យាន បានទទូចថារូបគាត់ធ្វើការជានិរសារឲ្យលោក ‟កុយ ឃួន″ ហៅ ‟ធុច″ មិនមែនលោក ‟កុយ ធួន″។ តែទោះជាយ៉ាងណាក៏ដោយ សាក្សីបានបញ្ជាក់ថា ‟កុយ ឃួន″ គឺជាប្រធានតំបន់ ៣០៤ និង ក្រោយមកក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលឋានៈទាំងពីរ និងឈ្មោះហៅក្រៅថា ‟ធុច″ គឺឆ្លុះបង្ហាញថាជាលោក ‟កុយ ធួន″ ។ ដូចគ្នានេះផងដែរ ដីកាដំណោះស្រាយបានរៀបរាប់ថា ក្នុងចំណោមឈ្មោះហៅក្រៅរបស់ កុយ ធួន គឺ ‟ឃួន″។ ហេតុដូចនេះ ក្នុងគោលបំណងចងក្រងរបាយការណ៍នេះ មេដឹកនាំដែលសាក្សី ពាន យាន បានសំដៅទៅលើនោះ គឺនឹងត្រូវបានសំដៅដូចគ្នាថាជា លោក ‟កុយ ធួន″។

3 While the Witness provide that he started living with Koy Thoun from 1967, 1968 or 1969, he also started that he moved from Rattanakiri to Kompong Thom in 1970.

4 See Case 002 KRT Trial Monitor, issue No.19, Hearing of Evidence Week 14 (18-20 April 2012).

5 See Case 002 KRT Trial Monitor, issue No.20, Hearing of Evidence Week 15 (23-26 April 2012).

6 See CASE 002 KRT TRIAL MONITOR, Issue No. 20, Hearing on Evidence Week 15 (23-26 April 2012).

7 *Prosecutor v. Milutinovic et al.* Case No. IT-05-87-T. ICTY Trial Chamber. “Decision on Evidence Tendered Through Sandra Mitchell and Frederick Abrahams” (1 September 2006). par. 16. 7-8. In this case, the ICTY TRial Chamber held that, “(t)he admission of summaries and reports created by non-parties is not affected by the rule against admitting summaries prepared by parties of statements given by potential witnesses, so such materials may be admitted pursuant to Rule 89 (C). These documents, however, are hearsay in nature, and thus would have to possess the necessary indicia of reliability in order to be admissible.”

8 *Prosecutor v. Gotovina et al.* Case No. IT-06-90-T. ICTY Trial Chamber I. “Judgement” (15 April 2011). par. 45. 27-28. In this case, the ICTY Trial Chamber ruled that official notes, “out-of-court statements prepared by non-parties and not taken for the purpose of the tribunal’s proceedings,” are probative and admitted them into evidence” (with the exception of the official notes of the two Accused that were excluded on the basis of the need to ensure fair trial rights).. “In evaluating the evidence, the Trial Chamber determined the weight to accord to each official note on a case-by-case basis.” However, “(A)s a rule, the Trial Chamber accorded the official notes little weight and did not rely on them except to the extent that they were corroborated by other evidence.”